ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី
លេខ ១០៧២.ស.ជ.ណ

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ២០១៥

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី
## ជម្រាបជូន

**-ឯកឧត្តម រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**
**-ឯឧត្តម រដ្ឋមន្ត្រីក្រសួងបរិស្ថាន**
**-ឯកឧត្តម រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**
**-ឯកឧត្តម អភិបាល នៃគណៈអភិបាលខេត្តកំពង់ធំ**
**-ឯកឧត្តម អភិបាល នៃគណៈអភិបាលខេត្តព្រះវិហារ**
**-ឯកឧត្តម អភិបាល នៃគណៈអភិបាលខេត្តសៀមរាប**

**កម្មវត្ថុ ៖** របាយការណ៍ស្តីពីលទ្ធផល នៃកិច្ចប្រជុំរបស់គណៈកម្មការអន្តរក្រសួងដើម្បីត្រួតពិនិត្យ វាស់វែង និងវាយតម្លៃសម្បទានដីសេដ្ឋកិច្ចចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០១៥។

**យោង ៖** -របាយការណ៍ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០១៥ របស់គណៈកម្មការអន្តរក្រសួងដើម្បីត្រួតពិនិត្យ វាស់វែង និងវាយតម្លៃសម្បទានដីសេដ្ឋកិច្ច

-ចំណារដ៏ខ្ពង់ខ្ពស់បំផុតរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ២០១៥។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ទីស្តីការគណៈរដ្ឋមន្ត្រីសូមជម្រាបជូន **ឯកឧត្តម** ជ្រាបថា៖ ចំពោះរបាយការណ៍របស់គណៈកម្មការអន្តរក្រសួងដើម្បីត្រួតពិនិត្យ វាស់វែង និងវាយតម្លៃសម្បទានដីសេដ្ឋកិច្ច ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០១៥ ទាក់ទងនឹងការវាយតម្លៃក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចចំនួន ១៨ ក្រុមហ៊ុន ស្ថិតក្នុងភូមិសាស្ត្រ ខេត្តកំពង់ធំ និងខេត្តព្រះវិហារ រាជរដ្ឋាភិបាលសម្រេចដូចខាងក្រោម៖

**-ខេត្តកំពង់ធំ**

**I-ក្រុមហ៊ុនដែលស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងបរិស្ថាន**

**១-ក្រុមហ៊ុន C.R.C.K.2 APHIVATH CAOUTCHOUC CO.,LTD ៖ (១)**

១- អនុញ្ញាតឲ្យក្រុមហ៊ុន C.R.C.K.2 APHIVATH CAOUT CHOUC CO.,LTD ដែលមានទីតាំងស្ថិតនៅក្នុងដែនជម្រកសត្វព្រៃបឹងពែរ ភូមិសាស្ត្រស្រុកស្ទោង ខេត្តកំពង់ធំ បន្តនីតិវិធី ហើយចុះកិច្ចសន្យាឡើងវិញ និងកែសម្រួលរយៈពេលវិនិយោគពី ៧០ (ចិតសិប) មកជា ៥០ (ហាសិប) ឆ្នាំ។

២- ប្រគល់ភារកិច្ចជូនក្រសួងបរិស្ថាន អាជ្ញាធរខេត្តកំពង់ធំ និងស្ថាប័នពាក់ព័ន្ធកំណត់ព្រំប្រទល់ដី (បញ្ជាក់និយាមកា) គម្រោងវិនិយោគដីសម្បទានក្រុមហ៊ុន C.R.C.K.2 APHIVATH CAOUT CHOUC CO.,LTD ស្ថិតនៅភូមិសាស្ត្រស្រុកស្ទោង ខេត្តកំពង់ធំ ឡើងវិញឲ្យបានច្បាស់លាស់។

**២-ក្រុមហ៊ុន ស៊ី.អ.ស៊ី.ខេ ២ អភិវឌ្ឍន៍កៅស៊ូ** ៖ (២)

១- អនុញ្ញាតឲ្យក្រុមហ៊ុន **ស៊ី.អ.ស៊ី.ខេ ២ អភិវឌ្ឍន៍កៅស៊ូ** ដែលមានទីតាំងស្ថិតនៅក្នុងតំបន់ដែនជម្រកសត្វព្រៃបឹងពែរ ភូមិសាស្ត្រខេត្តកំពង់ធំ និងខេត្តសៀមរាប បន្តនីតិវិធី ហើយចុះកិច្ចសន្យាឡើងវិញ និងកែសម្រួលរយៈពេលវិនិយោគពី **៧០ (ចិតសិប) ឆ្នាំ** មកជា **៥០ (ហាសិប) ឆ្នាំ**។

២- ប្រគល់ភារកិច្ចជូនក្រសួងបរិស្ថាន អាជ្ញាធរខេត្តកំពង់ធំ និងខេត្តសៀមរាប និងស្ថាប័នពាក់ព័ន្ធកំណត់ព្រំប្រទល់ដី **(បញ្ជាក់និយាមកា)** គម្រោងវិនិយោគដីសម្បទានក្រុមហ៊ុន **ស៊ី.អ.ស៊ី.ខេ ២ អភិវឌ្ឍន៍កៅស៊ូ** ស្ថិតក្នុងតំបន់ដែនជម្រកសត្វព្រៃបឹងពែរ ភូមិសាស្ត្រខេត្តកំពង់ធំ និងខេត្តសៀមរាប ឡើងវិញឲ្យបានច្បាស់លាស់។

**៣-ក្រុមហ៊ុន បៀន ហៀក អ៊ិនវេសមេន** ៖ (១)

១- អនុញ្ញាតឲ្យក្រុមហ៊ុន **បៀន ហៀក អ៊ិនវេសមេន** ដែលមានទីតាំងស្ថិតក្នុងតំបន់ប្រើប្រាស់ដោយចីរភាពនៃដែនជម្រកសត្វព្រៃបឹងពែរ ឃុំសាគ្រាម ស្រុកប្រាសាទបាល្ល័ង្គ និងស្រុកស្ទោង ខេត្តកំពង់ធំ បន្តនីតិវិធី ហើយចុះកិច្ចសន្យាឡើងវិញ និងកែសម្រួលរយៈពេលវិនិយោគពី **៧០ (ចិតសិប) ឆ្នាំ** មកជា **៥០ (ហាសិប) ឆ្នាំ**។

២- ប្រគល់ភារកិច្ចជូនក្រសួងបរិស្ថាន អាជ្ញាធរខេត្តកំពង់ធំ និងស្ថាប័នពាក់ព័ន្ធកំណត់ព្រំប្រទល់ដី **(បញ្ជាក់និយាមកា)** គម្រោងវិនិយោគដីសម្បទានក្រុមហ៊ុន **បៀន ហៀក អ៊ិនវេសមេន** ដែលមានទីតាំងស្ថិតក្នុងតំបន់ប្រើប្រាស់ដោយចីរភាពនៃដែនជម្រកសត្វព្រៃបឹងពែរ ឃុំសាគ្រាម ស្រុកប្រាសាទបាល្ល័ង្គ និងស្រុកស្ទោង ខេត្តកំពង់ធំ ឡើងវិញឲ្យបានច្បាស់លាស់។

**៤-ក្រុមហ៊ុន បៀន ហៀក អ៊ិនវេសមេន ខូអិលធីឌី** ៖ (២)

១- អនុញ្ញាតឲ្យក្រុមហ៊ុន **បៀន ហៀក អ៊ិនវេសមេន ខូអិលធីឌី** ដែលមានទីតាំងស្ថិតនៅក្នុងតំបន់ដែនជម្រកសត្វព្រៃបឹងពែរ ភូមិសាស្ត្រ ខេត្តកំពង់ធំ ខេត្តព្រះវិហារ និងខេត្តសៀមរាប បន្តនីតិវិធី ហើយចុះកិច្ចសន្យាឡើងវិញ និងកែសម្រួលរយៈពេលវិនិយោគពី **៧០ (ចិតសិប) ឆ្នាំ**មកជា **៥០ (ហាសិប) ឆ្នាំ**។

២-ប្រគល់ភារកិច្ចជូនក្រសួងបរិស្ថាន អាជ្ញាធរខេត្តកំពង់ធំ ខេត្តព្រះវិហារ ខេត្តសៀមរាប និងស្ថាប័នពាក់ព័ន្ធកំណត់ព្រំប្រទល់ដី **(បញ្ជាក់និយាមកា)** គម្រោងវិនិយោគដីសម្បទានក្រុមហ៊ុន **បៀន ហៀក អ៊ិនវេសមេន ខូអិលធីឌី** ដែលមានទីតាំងស្ថិតនៅក្នុងតំបន់ដែនជម្រកសត្វព្រៃបឹងពែរ ភូមិសាស្ត្រ ខេត្តកំពង់ធំ ខេត្តព្រះវិហារ និងខេត្តសៀមរាប ឡើងវិញឲ្យបានច្បាស់លាស់។

**៥-ក្រុមហ៊ុន** CAOUTCHOUC MEKONG CO.,LTD ៖

១- អនុញ្ញាតឲ្យក្រុមហ៊ុន CAOUTCHOUC MEKONG CO.,LTD ដែលមានទីតាំងស្ថិតនៅក្នុងតំបន់ដែនជម្រកសត្វព្រៃបឹងពែរ ក្នុងភូមិសាស្ត្រ ស្រុកប្រាសាទបាល្ល័ង្គ ខេត្តកំពង់ធំ បន្តនីតិវិធីលើផ្ទៃដី

ដែលបានដោះស្រាយផលប៉ះពាល់រួច ហើយចុះកិច្ចសន្យាឡើងវិញ និងកែសម្រួលរយៈពេលវិនិយោគពី **៧០ (ចិតសិប) ឆ្នាំ** មកជា **៥០ (ហាសិប) ឆ្នាំ**។

២-ប្រគល់ភារកិច្ចជូនបរិស្ថាន អាជ្ញាធរខេត្តកំពង់ធំ និងស្ថាប័នពាក់ព័ន្ធកំណត់ព្រំប្រទល់ដី (**បញ្ជាក់និយាមកា**) គម្រោងវិនិយោគដីសម្បទានក្រុមហ៊ុន CAOUTCHOUC MEKONG CO.,LTD ស្ថិតក្នុងតំបន់ដែនជម្រកសត្វព្រៃបឹងពែរ ក្នុងភូមិសាស្ត្រ ស្រុកប្រាសាទបាល្ល័ង្គ ខេត្តកំពង់ធំ ឡើងវិញឱ្យបានច្បាស់លាស់។

៣-កែសម្រួលអនុក្រឹត្យលេខ **៨៦.អនក្រ.បក** ចុះថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ២០១០ របស់រាជរដ្ឋាភិបាល ស្តីពីការកំណត់តំបន់គ្រប់គ្រងក្នុងតំបន់ការពារធម្មជាតិ ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព និងអនុក្រឹត្យលេខ **៩៥.អនក្រ.បក** ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១០ របស់រាជរដ្ឋាភិបាល ស្តីពីការធ្វើអនុបយោគ ផ្ទៃដីទំហំ **៨.០០០ (ប្រាំបីពាន់) ហិកតា** ក្នុងតំបន់ដែនជម្រកសត្វព្រៃបឹងពែរ ស្ថិតនៅក្នុងភូមិសាស្ត្រ ស្រុកប្រាសាទបាល្ល័ង្គ ខេត្តកំពង់ធំ។

៤-ប្រគល់ផ្ទៃដីកាត់ចេញទាំងអស់ជូនក្រសួងបរិស្ថាន និងអាជ្ញាធរខេត្តកំពង់ធំ គ្រប់គ្រង។

៥-ប្រគល់ភារកិច្ចជូនគណៈកម្មការអន្តរក្រសួងដើម្បីត្រួតពិនិត្យ វាស់វែង និងវាយតម្លៃសម្បទានដីសេដ្ឋកិច្ច ក្រសួងបរិស្ថាន និងអាជ្ញាធរខេត្ត រៀបចំបែបបទបច្ចេកទេស គ្រប់គ្រងផ្ទៃដីដែលមានផលប៉ះពាល់ស្របតាមលិខិតបទដ្ឋានជាធរមាន។

**៦-ក្រុមហ៊ុន សម្បត្តិផ្លេធីណឹម ៖**

១-អនុញ្ញាតឲ្យក្រុមហ៊ុន **សម្បត្តិផ្លេធីណឹម** ដែលមានទីតាំងស្ថិតនៅក្នុងតំបន់ដែនជម្រកសត្វព្រៃបឹងពែរ ក្នុងភូមិសាស្ត្រ ឃុំមានជ័យ ស្រុកសណ្តាន់ ខេត្តកំពង់ធំ បន្តនីតិវិធី ហើយចុះកិច្ចសន្យាឡើងវិញ ដោយកែសម្រួលរយៈពេលវិនិយោគពី **៧០ (ចិតសិប) ឆ្នាំ** មកជា **៥០ (ហាសិប) ឆ្នាំ**។

២-ប្រគល់ភារកិច្ចជូនក្រសួងបរិស្ថាន អាជ្ញាធរខេត្តកំពង់ធំ និងស្ថាប័នពាក់ព័ន្ធកំណត់ព្រំប្រទល់ដី (**បញ្ជាក់និយាមកា**) គម្រោងវិនិយោគដីសម្បទានក្រុមហ៊ុន **សម្បត្តិផ្លេធីណឹម** ដែលមានទីតាំងស្ថិតនៅក្នុងតំបន់ដែនជម្រកសត្វព្រៃបឹងពែរ ក្នុងភូមិសាស្ត្រ ឃុំមានជ័យ ស្រុកសណ្តាន់ ខេត្តកំពង់ធំ ឡើងវិញឲ្យបានច្បាស់លាស់។

**៧-ក្រុមហ៊ុន ប៉ោ ខូច អភិវឌ្ឍន៍ គ្រុប ខូអិលធីឌី ៖**

១-អនុញ្ញាតឲ្យក្រុមហ៊ុន **ប៉ោ ខូច អភិវឌ្ឍន៍គ្រុប ខូអិលធីឌី** ដែលមានទីតាំងស្ថិតនៅក្នុងតំបន់ដែនជម្រកសត្វព្រៃបឹងពែរ ស្ថិតនៅក្នុងភូមិសាស្ត្រ ខេត្តព្រះវិហារ និងខេត្តកំពង់ធំ បន្តនីតិវិធីលើដីដែលបានដោះស្រាយផលប៉ះពាល់រួច ហើយចុះកិច្ចសន្យាឡើងវិញ និងកែសម្រួលរយៈពេលវិនិយោគពី **៧០ (ចិតសិប) ឆ្នាំ** មកជា **៥០ (ហាសិប) ឆ្នាំ**។

២-ប្រគល់ភារកិច្ចជូនក្រសួងបរិស្ថាន អាជ្ញាធរខេត្តកំពង់ធំ ខេត្តព្រះវិហារ និងស្ថាប័នពាក់ព័ន្ធកំណត់ព្រំប្រទល់ដី (**បញ្ជាក់និយាមកា**) គម្រោងវិនិយោគដីសម្បទានក្រុមហ៊ុន **ប៉ោ ខូច អភិវឌ្ឍន៍គ្រុប ខូអិលធីឌី** ដែលមានទីតាំងស្ថិតនៅក្នុងតំបន់ដែនជម្រកសត្វព្រៃបឹងពែរ ស្ថិតនៅក្នុងភូមិសាស្ត្រ ខេត្តព្រះវិហារ និងខេត្តកំពង់ធំ ឡើងវិញឲ្យបានច្បាស់លាស់ ហើយជំរុញការចុះកិច្ចសន្យា ការចុះបញ្ជីដីរដ្ឋ និងការអនុវត្តផែនការមេឱ្យបានហ្មត់ចត់។

**៨-ក្រុមហ៊ុន ទេពី អាក្រូ វិនិយោគ (TEPI AGRO INVESTMENT CO.,LTD) ៖**

១-អនុញ្ញាតឲ្យក្រុមហ៊ុន **ទេពី អាក្រូ វិនិយោគ** (TEPI AGRO INVESTMENT CO.,LTD) ដែលមានទីតាំងស្ថិតនៅក្នុងដែនជម្រកសត្វព្រៃបឹងពែរ ភូមិសាស្ត្រ ស្រុកប្រាសាទបាល្ល័ង្ក និងស្រុកសណ្ដាន់ ខេត្តកំពង់ធំ បន្តនីតិវិធី ហើយចុះកិច្ចសន្យាឡើងវិញ និងកែសម្រួលរយៈពេលវិនិយោគពី ៧០ (ចិតសិប) ឆ្នាំ មកជា ៥០ (ហាសិប) ឆ្នាំ។

២-ប្រគល់ភារកិច្ចជូនក្រសួងបរិស្ថាន អាជ្ញាធរខេត្តកំពង់ធំ និងស្ថាប័នពាក់ព័ន្ធកំណត់ព្រំប្រទល់ដី (បញ្ជាក់និយាមកា) គម្រោងវិនិយោគដីសម្បទានក្រុមហ៊ុន **ទេពី អាក្រូ វិនិយោគ** (TEPI AGRO INVESTMENT CO.,LTD) ដែលមានទីតាំងស្ថិតនៅក្នុងដែនជម្រកសត្វព្រៃបឹងពែរ ភូមិសាស្ត្រ ស្រុកប្រាសាទបាល្ល័ង្ក និងស្រុកសណ្ដាន់ ខេត្តកំពង់ធំ ឡើងវិញឲ្យបានច្បាស់លាស់។

**៩-ក្រុមហ៊ុន អាន ម៉ាឌី គ្រុប ខូ អិលធីឌី (AN MADY GROUP Co., Ltd) ៖**

១-អនុញ្ញាតឲ្យក្រុមហ៊ុន **អាន ម៉ាឌី គ្រុប ខូ អិលធីឌី** ស្ថិតនៅដែលមានទីតាំងនៅក្នុងដែនជម្រកសត្វព្រៃបឹងពែរ ភូមិសាស្ត្រខេត្តព្រះវិហារ និងខេត្តកំពង់ធំ បន្តនីតិវិធីលើផ្ទៃដីដោះស្រាយផលប៉ះពាល់រួច ហើយចុះកិច្ចសន្យាឡើងវិញ និងកែសម្រួលរយៈពេលវិនិយោគពី ៩០ (កៅសិប) ឆ្នាំ មកជា ៥០ (ហាសិប) ឆ្នាំ។

២-ប្រគល់ភារកិច្ចជូនក្រសួងបរិស្ថាន អាជ្ញាធរខេត្តកំពង់ធំ ខេត្តព្រះវិហារ និងស្ថាប័នពាក់ព័ន្ធកំណត់ព្រំប្រទល់ដី (បញ្ជាក់និយាមកា) គម្រោងវិនិយោគដីសម្បទានក្រុមហ៊ុន **អាន ម៉ាឌី គ្រុប ខូ អិលធីឌី** ដែលមានទីតាំងនៅក្នុងដែនជម្រកសត្វព្រៃបឹងពែរ ភូមិសាស្ត្រខេត្តព្រះវិហារ និងខេត្តកំពង់ធំ ឡើងវិញឲ្យបានច្បាស់លាស់។

៣-កែសម្រួលអនុក្រឹត្យលេខ **១២៨.អនក្រ.បក** ចុះថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០០៩ របស់រាជរដ្ឋាភិបាល ស្ដីពីការកំណត់តំបន់គ្រប់គ្រងក្នុងតំបន់ការពារធម្មជាតិ ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព អនុក្រឹត្យលេខ **៩៧.អនក្រ.បក** ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ២០១០ របស់រាជរដ្ឋាភិបាល ស្ដីពីការធ្វើវិសោធនកម្មអនុក្រឹត្យលេខ **១២៨ អនក្រ.បក** ចុះថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០០៩ ស្ដីពីការកំណត់តំបន់គ្រប់គ្រង ក្នុងតំបន់ការពារធម្មជាតិ ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព អនុក្រឹត្យលេខ **១៨៤.អនក្រ.បក** ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ២០០៩ របស់រាជរដ្ឋាភិបាល ស្ដីពីការធ្វើអនុបយោគផ្ទៃដីទំហំ **៩.៩៩៣ (ប្រាំបួនពាន់ប្រាំបួនរយកៅសិបបី) ហិកតា** ស្ថិតក្នុងតំបន់ដែនជម្រកសត្វព្រៃបឹងពែរ ស្រុករវៀង ខេត្តព្រះវិហារ និងស្រុកសណ្ដាន់ ខេត្តកំពង់ធំ និងអនុក្រឹត្យលេខ **១០២.អនក្រ.បក** ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០១០ របស់រាជរដ្ឋាភិបាល ស្ដីពីការធ្វើវិសោធនកម្មអនុក្រឹត្យលេខ **១៨៤ អនក្រ.បក** ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ២០០៩ ស្ដីពីការធ្វើអនុបយោគ ផ្ទៃដីទំហំ **៩.៩៩៣ (ប្រាំបួនពាន់ប្រាំបួនរយកៅសិបបី) ហិកតា** ស្ថិតក្នុងដែនជម្រកសត្វព្រៃបឹងពែរ ស្រុករវៀង ខេត្តព្រះវិហារ និងស្រុកសណ្ដាន់ ខេត្តកំពង់ធំ។

៤-ប្រគល់ផ្ទៃដីកាត់ចេញទាំងអស់ជូនក្រសួងបរិស្ថាន អាជ្ញាធរខេត្តកំពង់ធំ និងខេត្តព្រះវិហារ គ្រប់គ្រង។

៥- ប្រគល់ភារកិច្ចជូនគណៈកម្មការអន្តរក្រសួងដើម្បីត្រួតពិនិត្យ វាស់វែង និងវាយតម្លៃសម្បទានដីសេដ្ឋកិច្ច ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងអាជ្ញាធរខេត្ត រៀបចំបែបបទបច្ចេកទេសគ្រប់គ្រងផ្ទៃដីដែលមានផលប៉ះពាល់ស្របតាមលិខិតបទដ្ឋានជាធរមាន។

**II- ក្រុមហ៊ុនដែលស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ៖**

**១០- ក្រុមហ៊ុន ប៊ី អិន អេ (ខេម) ខម B N A (CAM) CORP ៖**

១- អនុញ្ញាតឲ្យក្រុមហ៊ុន ប៊ី អិន អេ (ខេម) ខម B N A (CAM) CORP ដែលមានទីតាំងស្ថិតនៅក្នុង ឃុំទីពោ ស្រុកសន្ទុក ខេត្តកំពង់ធំ បន្តនីតិវិធីដោយទុករយៈពេល ០១ (មួយ) ឆ្នាំ ដើម្បីតាមដានវឌ្ឍនភាព និងកែសម្រួលរយៈពេលវិនិយោគពី ៧០ (ចិតសិប) ឆ្នាំ មកជា ៥០ (ហាសិប) ឆ្នាំ។

២- ប្រគល់ជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងអាជ្ញាធរខេត្តកំពង់ធំ ត្រួតពិនិត្យ តាមដានអំពីវឌ្ឍនភាពរបស់ក្រុមហ៊ុននេះឲ្យបានហ្មត់ចត់បំផុត។ ក្នុងករណីដែលក្រុមហ៊ុនមិនបានអនុវត្តត្រឹមត្រូវក្នុងរយៈពេលកំណត់ខាងលើ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវរាយការណ៍ជូនគណៈកម្មការអន្តរក្រសួងដើម្បីមានវិធានការ។

**១១- ក្រុមហ៊ុន កុល វាសនា អ៊ិនវេសមេន ខូ អិលធីឌី ៖**

១- អនុញ្ញាតឲ្យក្រុមហ៊ុន **កុល វាសនា អ៊ិនវេសមេន ខូ អិលធីឌី** (Kol Veasna Investment Co.,Ltd) ស្ថិតនៅស្រុកប្រាសាទបល្ល័ង្គ ខេត្តកំពង់ធំ បន្តនីតិវិធីដោយទុករយៈពេល ០៣ (បី) ខែ ដើម្បីឱ្យក្រុមហ៊ុនមកបង់ថ្លៃសម្បទានសេដ្ឋកិច្ចជូនរដ្ឋ និងកែសម្រួលរយៈពេលវិនិយោគពី **៧០ (ចិតសិប) ឆ្នាំ** មកជា **៥០ (ហាសិប) ឆ្នាំ**។

២- ប្រគល់ជូនក្រសួងកសិកម្ម និងអាជ្ញាធរខេត្តកំពង់ធំ ត្រួតពិនិត្យ តាមដានអំពីវឌ្ឍនភាពរបស់ក្រុមហ៊ុននេះឲ្យបានហ្មត់ចត់បំផុត។ ក្នុងករណីដែលក្រុមហ៊ុនមិនបានអនុវត្តត្រឹមត្រូវក្នុងរយៈពេលកំណត់ខាងលើ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវរាយការណ៍ជូនគណៈកម្មការអន្តរក្រសួងដើម្បីមានវិធានការ។

**១២- ក្រុមហ៊ុន TAN BIEN KAMPONG THOM APHIVATH CAOUTCHOUC Co.,Ltd ៖**

១- អនុញ្ញាតឲ្យក្រុមហ៊ុន TAN BIEN KAMPONG THOM APHIVATH CAOUTCHOUC Co.,Ltd ដែលមានទីតាំងស្ថិតនៅឃុំក្រយា ស្រុកសន្ទុក ខេត្តកំពង់ធំ បន្តនីតិវិធី និងចុះកិច្ចសន្យាឡើងវិញ និងកែសម្រួលរយៈពេលវិនិយោគពី ៧០ (ចិតសិប) ឆ្នាំ មកជា ៥០ (ហាសិប) ឆ្នាំ។

២- ប្រគល់ភារកិច្ចជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អាជ្ញាធរខេត្តកំពង់ធំ និងស្ថាប័នពាក់ព័ន្ធ កំណត់ព្រំប្រទល់ដី (បញ្ជាក់និយាមកា) គម្រោងវិនិយោគសម្បទានដីសេដ្ឋកិច្ចក្រុមហ៊ុន TAN BIEN KAMPONG THOM APHIVATH CAOUTCHOUC Co.,Ltd ដែលមានទីតាំងស្ថិតនៅឃុំក្រយា ស្រុកសន្ទុក ខេត្តកំពង់ធំ ឡើងវិញឲ្យបានច្បាស់លាស់។

៣- ប្រគល់ជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ធ្វើការផាកពិន័យចំពោះក្រុមហ៊ុនដែលបានឈូសឆាយចូលក្នុងដីទួនាប់ដងអូរ និងដីព្រៃរក្សាការពារ។

**១៣-ក្រុមហ៊ុន បារ៉ា កំពង់ធំ អភិវឌ្ឍន៍ កៅស៊ូ៖**

១-អនុញ្ញាតឲ្យក្រុមហ៊ុន បារ៉ា កំពង់ធំ អភិវឌ្ឍន៍ កៅស៊ូ (BARIA KAMPONG THOMAPHIVATH CAOUTCHOUC Co.,Ltd) ដែលមានទីតាំងស្ថិតនៅក្នុងស្រុកសន្ទុក ខេត្តកំពង់ធំ បន្តនីតិវិធី និងចុះកិច្ចសន្យាឡើងវិញ និងកែសម្រួលរយៈពេលវិនិយោគពី ៧០ (ចិតសិប) ឆ្នាំ មកជា ៥០ (ហាសិប) ឆ្នាំ។

២-ប្រគល់ភារកិច្ចជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អាជ្ញាធរខេត្តកំពង់ធំ និងស្ថាប័នពាក់ព័ន្ធ កំណត់ព្រំប្រទល់ដី (បញ្ជាក់និយាមកា) គម្រោងវិនិយោគសម្បទានដីសេដ្ឋកិច្ចក្រុមហ៊ុន **បារ៉ា កំពង់ធំ អភិវឌ្ឍន៍ កៅស៊ូ** (BARIA KAMPONG THOMAPHIVATH CAOUTCHOUC Co.,Ltd) ដែលមានទីតាំងស្ថិតនៅក្នុងស្រុកសន្ទុក ខេត្តកំពង់ធំ ឡើងវិញឲ្យបានច្បាស់លាស់។

៣-ប្រគល់ជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ធ្វើការជាកពិន័យចំពោះក្រុមហ៊ុនដែលបានឈូសឆាយចូលក្នុងដីទ្រនាប់ដងអូរ និងដីព្រៃរក្សាការពារ។

**១៤-ក្រុមហ៊ុន ភឿក វ៉ា កំពង់ធំ អភិវឌ្ឍន៍ កៅស៊ូ** (PHOUC HOA KAMPONG THOM APHIVATH CAOUCTCHOUC Co.,Ltd ៖

១-អនុញ្ញាតឲ្យក្រុមហ៊ុន **ភឿក វ៉ា កំពង់ធំ អភិវឌ្ឍន៍ កៅស៊ូ** (PHOUC HOA KAMPONG THOM APHIVATH CAOUTCHOUC CO.,LTD) ដែលមានទីតាំងស្ថិតនៅ ឃុំបឹងល្វា និងឃុំក្រយា ស្រុកសន្ទុក ខេត្តកំពង់ធំ បន្តនីតិវិធី និងចុះកិច្ចសន្យាឡើងវិញ និងកែសម្រួលរយៈពេលវិនិយោគពី ៧០ (ចិតសិប) ឆ្នាំ មកជា ៥០ (ហាសិប) ឆ្នាំ។

២-ប្រគល់ភារកិច្ចជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អាជ្ញាធរខេត្តកំពង់ធំ និងស្ថាប័នពាក់ព័ន្ធ កំណត់ព្រំប្រទល់ដី (បញ្ជាក់និយាមកា) គម្រោងវិនិយោគសម្បទានដីសេដ្ឋកិច្ចក្រុមហ៊ុន **ភឿក វ៉ា កំពង់ធំ អភិវឌ្ឍន៍ កៅស៊ូ** (PHOUC HOA KAMPONG THOM APHIVATH CAOUTCHOUC CO.,LTD) ដែលមានទីតាំងស្ថិតនៅ ឃុំបឹងល្វា និងឃុំក្រយា ស្រុកសន្ទុក ខេត្តកំពង់ធំ ឡើងវិញឲ្យបានច្បាស់លាស់។

៣-ប្រគល់ជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ធ្វើការជាកពិន័យចំពោះក្រុមហ៊ុនដែលបានឈូសឆាយចូលក្នុងដីទ្រនាប់ដងអូរ និងដីព្រៃរក្សាការពារ។

**១៥-ក្រុមហ៊ុន ឫទ្ធីមុនី សំណាងលាភ ខូអិលធីឌី** (RITHYMONY SAMNANGLEAP Co.,LTD) ៖

១-អនុញ្ញាតឲ្យក្រុមហ៊ុន **ឫទ្ធីមុនី សំណាងលាភ ខូអិលធីឌី** (RITHYMONY SAMNANGLEAP Co.,LTD) ដែលមានទីតាំងស្ថិតនៅក្នុង ឃុំក្រយា ស្រុកសន្ទុក ខេត្តកំពង់ធំ បន្តនីតិវិធី និងកែសម្រួលរយៈពេលវិនិយោគពី ៧០ (ចិតសិប) ឆ្នាំ មកជា ៥០ (ហាសិប) ឆ្នាំ ។

២-ប្រគល់ភារកិច្ចជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អាជ្ញាធរខេត្តកំពង់ធំ និងស្ថាប័នពាក់ព័ន្ធ កំណត់ព្រំប្រទល់ដី (បញ្ជាក់និយាមកា) គម្រោងវិនិយោគសម្បទានដីសេដ្ឋកិច្ចក្រុមហ៊ុន **ឫទ្ធីមុនី សំណាងលាភ ខូអិលធីឌី** (RITHYMONY SAMNANGLEAP Co.,LTD) ដែលមានទីតាំងស្ថិតនៅក្នុងឃុំក្រយា ស្រុកសន្ទុក ខេត្តកំពង់ធំ ឡើងវិញឲ្យបានច្បាស់លាស់។

**១៦-ក្រុមហ៊ុន ស៊ី ស៊ី វី (C C V Co.,Ltd) ៖**

១-អនុញ្ញាតឲ្យក្រុមហ៊ុន ស៊ី ស៊ី វី (C C V Co.,Ltd) ដែលមានទីតាំងស្ថិតនៅក្នុង ឃុំក្រយា ស្រុកសន្ទុក ខេត្តកំពង់ធំ បន្តនីតិវិធីលើផ្ទៃដីដែលបានដោះស្រាយផលប៉ះពាល់រួច ហើយចុះកិច្ចសន្យាឡើងវិញ និងកែសម្រួលរយៈពេលវិនិយោគពី ៧០ (ចិតសិប) ឆ្នាំ មកជា ៥០ (ហាសិប) ឆ្នាំ។

២-ប្រគល់ភារកិច្ចជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អាជ្ញាធរខេត្តកំពង់ធំ និងស្ថាប័នពាក់ព័ន្ធ កំណត់ព្រំប្រទល់ដី (បញ្ជាក់និយាមកា) គម្រោងវិនិយោគសម្បទានដីសេដ្ឋកិច្ចក្រុមហ៊ុន ស៊ី ស៊ី វី (C C V CO.,Ltd) ដែលមានទីតាំងស្ថិតនៅក្នុងឃុំក្រយា ស្រុកសន្ទុក ខេត្តកំពង់ធំឡើងវិញឲ្យបានច្បាស់លាស់។

៣-ប្រគល់ផ្ទៃដីកាត់ចេញទាំងអស់ជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អាជ្ញាធរខេត្តកំពង់ធំគ្រប់គ្រង។

៤-ប្រគល់ភារកិច្ចជូនគណៈកម្មការអន្តរក្រសួងដើម្បីត្រួតពិនិត្យ វាស់វែង និងវាយតម្លៃសម្បទានដីសេដ្ឋកិច្ច ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងអាជ្ញាធរខេត្ត រៀបចំបែបបទបច្ចេកទេសគ្រប់គ្រងផ្ទៃដីដែលមានផលប៉ះពាល់ស្របតាមលិខិតបទដ្ឋានជាធរមាន។

**១៧-ក្រុមហ៊ុន ស៊ី អ ស៊ី ខេ អភិវឌ្ឍន៍ កៅស៊ូ (C.R.C.K APHIVATH CAOUTCHOUC CO.,LTD) ៖**

១-អនុញ្ញាតឲ្យក្រុមហ៊ុន ស៊ី អ ស៊ី ខេ **អភិវឌ្ឍន៍ កៅស៊ូ** (C.R.C.K APHIVATH CAOUTCHOUC CO.,LTD) ដែលមានទីតាំងស្ថិតនៅក្នុង ស្រុកសណ្តាន់ ខេត្តកំពង់ធំ បន្តនីតិវិធីលើដីដែលបានដោះស្រាយផលប៉ះពាល់រួច ហើយចុះកិច្ចសន្យាឡើងវិញ និងកែសម្រួលរយៈពេលវិនិយោគពី **៧០ (ចិតសិប) ឆ្នាំ** មកជា ៥០ (ហាសិប) ឆ្នាំ។

២-ប្រគល់ភារកិច្ចជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អាជ្ញាធរខេត្តកំពង់ធំ និងស្ថាប័នពាក់ព័ន្ធកំណត់ព្រំប្រទល់ដី (បញ្ជាក់និយាមកា) គម្រោងវិនិយោគសម្បទានដីសេដ្ឋកិច្ចក្រុមហ៊ុន **ស៊ី អ ស៊ី ខេ អភិវឌ្ឍន៍** កៅស៊ូ (C.R.C.K APHIVATH CAOUTCHOUC CO.,LTD) ដែលមានទីតាំងស្ថិតនៅក្នុងស្រុកសណ្តាន់ ខេត្តកំពង់ធំ ឡើងវិញឲ្យបានច្បាស់លាស់។

៣-ប្រគល់ជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ធ្វើការផាកពិន័យចំពោះក្រុមហ៊ុនដែលបានឈូសឆាយចូលក្នុងដីព្រៃសហគមន៍។

៤-ប្រគល់ភារកិច្ចជូនគណៈកម្មការអន្តរក្រសួងដើម្បីត្រួតពិនិត្យ វាស់វែង និងវាយតម្លៃសម្បទានដីសេដ្ឋកិច្ច ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងអាជ្ញាធរខេត្ត រៀបចំបែបបទបច្ចេកទេសគ្រប់គ្រងផ្ទៃដីដែលមានផលប៉ះពាល់ស្របតាមលិខិតបទដ្ឋានជាធរមាន។

**១៨-ក្រុមហ៊ុន ហ្គោល ហ្វ៊យសុន (ខេមបូឌា) អេ/ស៊ី អ៊ីមផត អិចផត និងខនស្ត្រាក់សិន ៖**

១-អនុញ្ញាតឲ្យក្រុមហ៊ុន ហ្គោល ហ្វ៊យសុន (ខេមបូឌា) អេ/ស៊ី អ៊ីមផត អិចផត និងខនស្ត្រាក់សិន ដែលមានទីតាំងស្ថិតនៅស្រុកសន្ទុក និងស្រុកប្រាសាទសំបូរ ខេត្តកំពង់ធំ បន្តនីតិវិធី ដោយចុះកិច្ចសន្យាឡើងវិញ និងកែសម្រួលរយៈពេលវិនិយោគពី ៧០ (ចិតសិប) ឆ្នាំ មកជា ៥០ (ហាសិប) ឆ្នាំ ។

២-ប្រគល់ភារកិច្ចជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អាជ្ញាធរខេត្តកំពង់ធំ និងស្ថាប័នពាក់ព័ន្ធកំណត់ព្រំប្រទល់ដី (បញ្ជាក់និយាមកា) គម្រោងវិនិយោគសម្បទានដីសេដ្ឋកិច្ចក្រុមហ៊ុន ហ្គោល

ហ្វ៊យសុន(ខេមបូឌា) អេ/ស៊ី អ៊ីមផត អិចផត និងខនស្ត្រាក់សិន ដែលមានទីតាំងស្ថិតនៅស្រុកសន្ទុក និងស្រុកប្រាសាទសំបូរ ខេត្តកំពង់ធំ ឡើងវិញឲ្យបានច្បាស់លាស់។

៣-ប្រគល់ជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ធ្វើការផាកពិន័យចំពោះក្រុមហ៊ុនដែលបាន ឈូសឆាយចូលក្នុងដីព្រៃរក្សាទុក។

សេចក្ដីដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តម** ជ្រាប និងចាត់ចែងអនុវត្ត។

**ជ.រដ្ឋមន្ត្រីទទួលបន្ទុកស្តីទីការគណៈរដ្ឋមន្ត្រី**
**អគ្គលេខាធិការ**

**តឹករ៉ែត សំរេច**

**ចម្លងជូនៈ**
- -ក្រសួងមហាផ្ទៃ
- -ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- -ក្រសួងធនធានទឹក និងឧតុនិយម
- -ក្រសួងរ៉ែ និងថាមពល
- -អង្គភាពប្រឆាំងអំពើពុករលួយ
- -ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- -ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- -ខុទ្ទកាល័យឯកឧត្តម-លោកជំទាវឧបនាយករដ្ឋមន្ត្រី
- -អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី
- -សមាជិកគណៈកម្មការអន្តរក្រសួងដើម្បីត្រួតពិនិត្យ វាស់វែង និងវាយតម្លៃសម្បទានដីសេដ្ឋកិច្ច
- -ឯកសារ-កាលប្បវត្តិ